**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ពិធីកាន់បិណ្ឌ៣នៅវត្តសិរីសោភា ហៅវត្តអង្គតាមិញ របស់ក្រសួងមុខងារសាធារណៈ

យោងតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដមរដ្ឋមន្ត្រី** ក្រសួងមុខងារសាធារណៈ

សូមជម្រាបជូន **ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ និងសប្បុរសជនទាំងអស់** មេត្តាជ្រាបថា ដើម្បីចូលរួមថែរក្សា និងលើកស្ទួយវប្បធម៌ ប្រពៃណីព្រះពុទ្ធសាសនា ឆ្នាំនេះ ក្រសួងមុខងារសាធារណៈ នឹងប្រារព្ធពិធីកាន់បិណ្ឌ៣នៅ **វត្តសិរីសោភា ហៅ វត្តអង្គតាមិញ** អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងមុខងារសាធារណៈ សូមអំពាវនាវដល់**ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ និងសប្បុរសជនទាំងអស់** មេត្តាចូលរួមក្នុងពិធីកាន់ បិណ្ឌ៣នេះឱ្យបានអធិកអធម និងចូលរួមចាប់មគ្គផលតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន តាមកម្មវិធីបុណ្យដូចខាងក្រោម៖

### កម្មវិធីបុណ្យ

-ថ្ងៃចន្ទ ២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២
ម៉ោង៣៖០០នាទីរសៀល ជួបជុំពុទ្ធបរិស័ទ ធ្វើបទនមស្សការ សមាទានសីល និងនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត។
-ថ្ងៃអង្គារ ៣រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២
ម៉ោង៧៖០០នាទីព្រឹក ប្រគេនជាយាគូព្រះសង្ឃ និងម៉ោង៩៖០០នាទីជួបជុំពុទ្ធបរិស័ទ ធ្វើបទនមស្សការសមាទានសីល រាប់បាត្រ និងវេរភត្តាហារព្រមទាំងទេយ្យទានប្រគេនព្រះសង្ឃ ដើម្បីធ្វើពិធីបង្សុកូល ឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធបុព្វការីជន ជាកិច្ចបង្ហើយបុណ្យ។

**សម្រាប់ការចូលរួមចាប់មគ្គផល៖** សូមផ្ទេរទៅគណនីABA Account No: 077666658 Name: SOY ROTANARK ឬចូលរួមចាប់មគ្គផលនៅនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៃក្រសួងមុខងារសាធារណៈ។

**ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

| | |
|---|---|
| ១.ឯកឧត្ដម ហង្ស ឆាំឆាន | លេខទូរស័ព្ទ ០១១ ៨១២ ៧០៥ |
| ២.ឯកឧត្ដម ហាស់ ប៊ុនថ្លុន | លេខទូរស័ព្ទ ០១៦ ៦៩៩ ៩៤៥ |
| ៣.ឯកឧត្ដម សយ រតនៈ | លេខទូរស័ព្ទ ០៧៧ ៦៦៦ ៦៥៨ |
| ៤.លោក សោម សាវេត | លេខទូរស័ព្ទ ០១៥ ២១៤ ៤៤៤ ឬ០១៧ ៤៩៤ ៣៤៣ |

សូមប្រសិទ្ធពរបវរសួស្ដីជូន **ឯកឧត្ដម លោកជំទាវ លោក លោកស្រីទាំងអស់** ជួបប្រទះតែនឹងសេចក្ដីសុខ និងសេចក្ដីចម្រើនគ្រប់ប្រការ ពិសេសគឺវៀរចាកផុតពីជំងឺកូវីដ-១៩ ព្រមទាំងសមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១១កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២